# Living the Lotus

## Buddhism in Everyday Life

3
2025
VOL. 234




Rissho Kosei-kai in India: Delhi, Gaya, and Assam

Living the Lotus
Vol. 234 (March 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

*President's Message*

# គុណបុណ្យនៃធម្មជាតិនិងចក្រវាល

ព្រះគ្រូនីវ៉ាណូ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## មនុស្សគឺជាអ្នកបំផ្លាញធម្មជាតិ

ឥឡូវនេះទោះជាមិននិយាយក៏យើងដឹងដែរ ថាយើងម្នាក់ៗរស់បាននេះគឺដោយសារអ្នកដទៃឬអ្វីៗទាំងអស់ក្រៅពីខ្លួនយើង។ជាពិសេ សប្រសិនបើគ្មានព្រះអាទិត្យ ឬទឹក ឬខ្យល់ទេកុំថាឡើយដល់ទៅមនុស្ស ទោះជាអ្វីក៏ដោយឱ្យតែមានជីវិតនឹងត្រូវស្លាប់អស់គ្មានសល់។និយាយតែប៉ុននេះយើងអាចយល់ន័យនៃចំណងជើង "គុណបុណ្យនៃធម្មជាតិនិងចក្រវាល" បានសព្វគ្រប់ស្រេចហើយ។

ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងមានទំនោរភ្លេចការដឹងគុណចំពោះពរជ័យនៃធម្មជាតិនិងចក្រវាល។ លើសពីនេះទៅទៀត មនុស្សដែលបញ្ញាមានការអភិវឌ្ឍន៍ខ្ពស់ មានមោទនភាពបំផុតថាខ្លួនឯងពូកែជាងនរណាៗ ហើយបន្តស្វែងរកភាពងាយស្រួលនិងផាសុកភាពដោយបំផ្លិចបំផ្លាញបរិស្ថាននៃផែនដី ។ មើលពីភ្នែករបស់ធម្មជាតិមនុស្សលោកគ្មានអ្វីក្រៅពី "អ្នកបំផ្លិចបំផ្លាញធម្មជាតិ" ឡើយ។

ព្រះគ្រូអាយុកាវ៉ា ហាគឹដូ (Hakudo Ayukawa) នៃពុទ្ធសាសនានិកាយរីនហៃ្ស (Rinzai) បានផ្តល់អនុសាសន៍ទៅលើភាពយង់ឃ្នងរបស់មនុស្សបែបកំប្លែងដោយប្រើគំនិតថាប្រសិនបើសត្វ និងរុក្ខជាតិផ្សេងទៀតចេះនិយាយ ពួកគេច្បាស់ជានឹងថា៖ "លោកមនុស្សអើយលោកមនុស្ស តាំងពីណាពីណើយូរណាស់មកហើយយើងរាល់គ្នាដឹងគុណផែនដីដែលបានពង្រស់យើងឱ្យរស់រានមានជីវិតនេះបណ្តើរខំថែរក្សាផែនដីនេះជា មួយគ្នាបណ្តើររហូតមកទល់នឹងពេលនេះ។ ចូរឈប់អាត្មានិយមដោយគ្រាន់តែអ្នកឆ្លាតវៃជាងពួកយើងបន្តិចនោះទៅ។" (ដកស្រង់ពី "Howa no Mado (បង្អួចនៃព្រះធម៌)"វត្ត ដៃហុងហ្សាំង ម្យោស៊ីនជី (Daihonzan Myo shinji)។ ព្រះគ្រូ អាយុកាវ៉ា បានបញ្ជាក់យ៉ាងច្បាស់ថាការដឹងគុណចំពោះផែនដីនិងធម្មជាតិ ហើយបញ្ជូនផែនដីដ៏ស្រស់ស្អាតទៅកាន់មនុស្សជំនាន់ក្រោយឯនោះទេទើបហៅថាប្រាជ្ញារបស់មនុស្សនោះ។

"រុក្ខជាតិ ដើមឈើ ទឹកដី សុទ្ធតែនឹងទៅនិព្វាន" "សត្វមានជីវិតទាំងអស់សុទ្ធតែមានធាតុជាព្រះពុទ្ធ" ។ ព្រះពុទ្ធសាសនារបស់ជប៉ុនថែងថាព្រៃភ្នំ ស្ទឹងទន្លេ រុក្ខជាតិ ដើមឈើ និងសព្វអ្វីដែលមានជីវិតគឺជាការបង្ហាញពីជីវិតរបស់ព្រះពុទ្ធដូចៗគ្នា។ ទស្សនវិទូអ៊ុម៉េហារ៉ា តាគេស៊ី (Takeshi Umehara) បានអំពាវនាវដោយសង្កត់ធ្ងន់ទៅលើតម្រូវ

ការបន្ទាន់ដើម្បីធ្វើឱ្យគំនិតនេះទៅជាឧត្តមគតិទូទៅសម្រាប់មនុស្សជាតិទាំងអស់ ដើម្បីឱ្យមនុស្សអាចទទួលអារម្មណ៍ដោយរាងកាយផ្ទាល់របស់ខ្លួននូវពរជ័យនៃធម្មជាតិនិងអាចគោរពធម្មជាតិជាថ្មីឡើងវិញបាន។

មនុស្សមានទម្លាប់អាក្រក់មួយគឺថាបើមិនទាន់ជួបបញ្ហាទេគេមិនគិតអ្វីមួយឱ្យបានស៊ីជម្រៅឡើយ ក៏ប៉ុន្តែខ្ញុំព្រះករុណាអាត្មាភាពគិតថា យើងទាំងអស់គ្នាត្រូវដឹងពីសារសំខាន់នៃ ព្រះអាទិត្យ ខ្យល់ និងទឹកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន មុនពេលដែលយើងជួបបញ្ហា ហើយប្រញាប់ពិចារណាឡើងវិញពីផ្លូវជីវិតរបស់យើងឱ្យបានហ្មត់ចត់

## សុភមង្គលដែលអាចនិយាយថា "អរគុណ"

នៅពេលដែលខ្ញុំព្រះករុណាអាត្មាភាពទៅធ្វើទស្សនកិច្ចនៅកោះអូហ្គាសាវ៉ារ៉ា (Ogasa wara) មួយរយៈមុន ខ្ញុំព្រះករុណាអាត្មាភាពចាំថាបានទទួលអារម្មណ៍រំភើបដោយភាពស្រស់ស្អាតនៃថ្ងៃរះ និងថ្ងៃលិចនៅជើងមេឃដែលមើលឃើញពីកប៉ាល់ ហើយខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ស្រស់ស្រាយ ដូចបានត្រូវលាងសំអាតជម្រះមន្ទិលចេញអស់។ក្នុងពេលតែមួយនោះដែរក៏មានអារម្មណ៍យ៉ាងខ្លាំងថាជីវិតយើងត្រូវបានធម្មជាតិថែរក្សា ។ មនុស្សមួយចំនួនអាចនឹងរំជើបរំជួលដោយការមើលទៅរុក្ខជាតិនិងផ្កាដែលខំរស់ខំរីកនៅក្នុងសួនច្បាររបស់ពួកគេ ។ ពេលខ្លះទៅ ការទទួលបានពីភាពរឹងមាំនៃផ្កាតូចៗពណ៌លឿងឈ្មោះតាំប៉ូៗ( dent de lion )ដែលខំរីកពីចន្លោះស្នាមប្រេះនៃផ្លូវថ្នល់ចាក់កៅស៊ូនូវភាពក្លាហានដើម្បីរស់នៅ ក៏ជាសញ្ញានៃការផ្សារផ្ជាប់ទៅនឹងជីវិតដែរ ។

មានគ្រូពេទ្យចិត្តសាស្ត្រម្នាក់និយាយថា ពេលដែលយើងដាក់ចិត្តយើងឱ្យទៅជិតផ្កា និងរុក្ខជាតិ ហើយក្លាយជារបស់តែមួយជាមួយវា នោះយើងច្រើនតែមានអារម្មណ៍ធូរស្រាល និងទទួលបានកម្លាំងកាយ ហើយយើងទទួលបានពរជ័យជាច្រើនពីធម្មជាតិ រួមមានព្រះអាទិត្យ ទឹកនិងខ្យល់។

នេះមានន័យថា ទោះបីជាមានការអាក់រអួល ការខ្វះខាត ឬការរំខានបន្តិចបន្តួចក៏ដោយ ក៏យើងអាចទទួលយកវាដោយក្តីរីករាយ ប្រសិ នបើយើងមានបេះដូងដឹងគុណ។ ហើយនៅពេលដែលយើងចេះគិតថា "សូមដឹងគុណ" យើងក៏ត្រូវបានវត្តសក្តិសិទ្ធិថែរក្សា។

ចាប់តាំងពីដើមដំបូងម្ល៉េះការដែលបានកើតមកជាមនុស្សដែលអាចត្រាស់ដឹងនូវសច្ចធម៌ ហើយការដែលអាចនៅរស់សព្វថ្ងៃនេះ អាចនិយាយបានថា គឺជា"ការដឹងគុណ"រួចស្រេចទៅហើយ។ ចូរយើងបន្តផ្សព្វផ្សាយសេចក្តីអំណរ និងគុណបុណ្យ ដែលសមាគមយើងនេះបានបង្ហាញតាំងពីពេលដែលបានបង្កើតឡើងជាមួយនឹងមនុស្សគ្រប់គ្នាឱ្យបានឮខ្ទរខ្ទា ដើម្បីការពារផែនដីរបស់មនុស្សគ្រប់គ្នា។

『កូសេ』 លេខខែមីនាឆ្នាំ២០២៥



# Rissho Kosei-kai International

**Make Every Encounter Matter**



## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp